# អំពីខចែងពីមជ្ឈត្តការ

## ABOUT THE ARBITRATION CLAUSE

ខចែងពីមជ្ឈត្តការ គឺជាការបញ្ជាក់របស់គូភាគីក្នុងការព្រមព្រៀងយកវិវាទរបស់ពួកគេទៅដោះស្រាយតាមយន្តការមជ្ឈត្តការ ។ ខចែងនេះអាចរារាំងដល់ភាគីណាមួយ ចង់កែប្រែនៅពេលក្រោយក្នុងការសំរេចដាក់ពាក្យបណ្តឹងទៅតុលាការបាន ។ ហេតុនេះតើត្រូវចែងខសំរាប់មជ្ឈត្តការយ៉ាងដូចម្តេចទើបមានសុពលភាព?

ខចែងពីមជ្ឈត្តការ អាចត្រូវបានកំណត់ក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងដោយឡែកនៅពេលបង្កើតកិច្ចសន្យាអាជីវកម្មអ្វីមួយ ឧទាហរណ៍ៈកិច្ចសន្យាធ្វើអាជីវកម្មកម្មសិទ្ធិបញ្ញា កិច្ចសន្យាក្រុមហ៊ុន (លក្ខន្តិកៈក្រុមហ៊ុន) កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ជាដើម ។ គូភាគីអាចចែងដោយសេរី តែត្រូវមានយ៉ាងតិចនូវពាក្យ"...មជ្ឈត្តការ..." ពីព្រោះវាអាចបញ្ជាក់ច្បាស់លាស់ និងផ្តល់សមត្ថកិច្ចក្នុងការយកយន្តការមជ្ឈត្តការសំរាប់ដោះស្រាយវិវាទរបស់ពួកគេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលខចែងមានភាពស្រពិចស្រពិល ឬប្រហាក់ប្រហែល ឬស្រដៀង ដូចជាថា ការផ្សះផ្សា ឬការសំរបសំរួល ឬការសំរុះសំរួល មិនមានន័យគ្រប់គ្រាន់ក្នុងការយល់ព្រមធ្វើមជ្ឈត្តការនោះទេ ហើយជាផលលំបាកខចែងនោះនឹងមិនចងកាតព្វកិច្ចក្នុងការប្រើប្រាស់យន្តការដោះស្រាយវិវាទនេះឡើយ និងភាគីវិវាទណាមួយនៅតែអាចជ្រើសរើសប្រព័ន្ធតុលាការដដែល។ លើសពីនេះ ខចែងមជ្ឈត្តការ ក៏ត្រូវចែងផងដែរនូវឈ្មោះមជ្ឈត្តករ (មជ្ឈត្តការបែបអាដហុក) ឬស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ (មជ្ឈត្តការបែបស្ថាប័ន) ឧទាហរណ៍ៈ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីនៅពេលមានវិវាទកើតឡើងភាគីវិវាទមួយគ្រាន់តែដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម (ពាក្យសុំសេវាកម្មអំពីមជ្ឈត្តកម្ម) ដល់ពួកគេ បន្ទាប់មកដំណើរការមជ្ឈត្តការនឹងចាប់ផ្តើម។ ក្រៅពីចំនុចទាំងនេះនៅមានទីកន្លែង ភាសា ច្បាប់ និងវិធានសំរាប់ដោះស្រាយ ។ល។ សុទ្ធតែត្រូវចែង ឬក៏កំណត់ជាមុន ដែលទាំងនេះគឺអាស្រ័យទៅលើសេវាកម្មរបស់មជ្ឈត្តករឬស្ថាប័នដែលបានជ្រើសរើស ។ ហេតុនេះ គូភាគីត្រូវពិនិត្យមើលគំរូនៃខចែង របស់ពួកគេជាមុន ឬធ្វើការពិភាក្សាជាមុន នៅពេលសំរេចជ្រើសរើស សេវាកម្មរបស់ពួកគេ ។



## គំរូខចែងអំពីមជ្ឈត្តការរបស់ ម.ជ.ម.

វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬ ការបញ្ចប់កិច្ចសន្យានេះត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈមណ្ឌលផ្នែកពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈមណ្ឌលផ្នែកពាណិជ្ជកម្ម ("វិធាន ម.ជ.ម.") ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

វេទិកាមជ្ឈត្តកម្ម ត្រូវមានមជ្ឈត្តករចំនួន_____*នាក់។
(*ចំនួនមជ្ឈត្តករត្រូវកំណត់ ជាចំនួនសេស)

ភាសានៃមជ្ឈត្តការគឺ_______។

ច្បាប់ដែលត្រូវយកមកអនុវត្តកិច្ចសន្យានេះត្រូវស្ថិតក្រោមបញ្ញត្តិច្បាប់នៃ____________**។ (**បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ)

## NCAC
## MODEL ARBITRATION CLAUSE

Any dispute arising out of or in connection with this contract, including any question regarding its existence, validity, performance or termination, shall be referred to and finally resolved by arbitration in the Kingdom of Cambodia in accordance with the Arbitration Rules of the National Commercial Arbitration Centre (NCAC) being in force at the time of commencement of arbitration and by reference in this clause the NCAC Rules are deemed to be incorporated as part of this contract.

The Tribunal shall consist of ____________* arbitrator(s). *State an odd number.

The language of the arbitration shall be _________.

□Applicable Law
This contract is governed by the laws of ________________*. * State the country or jurisdiction.

ជារួមដើម្បីអាចដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការបាន ខចែងពីមជ្ឈត្តការដែលមាននៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងដោយឡែករបស់គូភាគី ត្រូវតែមានភាពច្បាស់លាស់នូវពាក្យមជ្ឈត្តការ ។ ការចែងដ៏ទៃទៀតសំរាប់លក្ខខណ្ឌនៃដំណើរការនីតិវិធីរបស់មជ្ឈត្តការ គឺអាស្រ័យទៅនឹងមជ្ឈត្តករ ឬស្ថាប័នដែលបានផ្តល់ជាគំរូ ឬកំណត់រួចហើយ ។ ការបំពេញនៅលក្ខខណ្ឌទាំងនេះគ្រប់គ្រាន់ អាចធ្វើឲ្យខចែងពីមជ្ឈត្តការមានសុពលភាព និងធានាបាននូវដំណើរការយន្តការមជ្ឈត្តការយ៉ាងប្រាកដ៕

**ដោយ៖ អុូវុឌ្ឍី ដោះស្រាយវិវាទ**
www.ouchvutthy.wordpress.com